ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១០/០៩ - ញូ វ៉ាយឌី ខេមបូឌា**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **កៅ ថាច**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លៈ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ញូ វ៉ាយឌី (ខេមបូឌា) ហ្គាមេន ខូ អិលធីឌី**
អាសយដ្ឋាន : ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០១២ ៩៥៩ ៦៥០ ទូរសារ : គ្មាន
តំណាងភាគីនិយោជក :

១- លោក Paul Zhou នាយកក្រុមហ៊ុន
២- កញ្ញា Chuon Channa ជាបុគ្គលិករដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សម្ព័ន្ធសហជីព_សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយឌី**
អាសយដ្ឋាន : ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
លេខទូរស័ព្ទ : ០១២ ២៨២ ៦៥៣ លេខទូរសារ : គ្មាន
តំណាងកម្មករនិយោជិត:

១- លោក អ៊ុំ វិសាល អគ្គលេខាធិការរង CCAWDU



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩...
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 7...
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

| | |
|---|---|
| ២- លោក អ៊ុង លាភ | ប្រធានសហជីព CCAWDU ប្រចាំរោងចក្រ |
| ៣- អ្នកស្រី អ៊ុំ ស្រី | លេខាធិការសហជីព |

បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាប្រចាំរោងចក្រនៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកលោក អ៊ុង លាភ ជាប្រធានសហជីព ចូលធ្វើការជាធម្មតាវិញ និងបើកប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃទទួលយកចូលធ្វើការវិញ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា កន្លងមកលោក អ៊ុង លាភ មិនស្តាប់តាមការចាត់ចែងពីថ្នាក់ដឹកនាំឡើយ ដូច្នេះក្រុមហ៊ុនមិនអាចបន្តកិច្ចសន្យាកាកងារជូនទៀតដែរ។

២- ថ្នាក់ដឹកនាំសហជីពនៅតែទាមទារឱ្យក្រុមហ៊ុនកុំឱ្យមានការរើសអើង និងបំបិទសិទ្ធិសេរីភាពរបស់កម្មករចូលជាសមាជិកសហជីព ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានការរើសអើង និងបំបិទសិទ្ធិសេរីភាពកម្មករ ដែលចង់ចូលជាសមាជិកសហជីពឡើយ ។

៣- សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាប្រចាំរោងចក្រនៅតែទាមទារ ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ១០០០ រៀលក្នុងមួយម៉ោង ហើយការធ្វើការបន្ថែមម៉ោង ផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ឱ្យឡើយ គឺក្រុមហ៊ុនអនុវត្តតាមសេចក្តីជូនដំណឹងលេខ ០១៧ ស.ក.ប.យ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០។

៤- សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាប្រចាំរោងចក្រនៅតែទាមទារ ឱ្យក្រុមហ៊ុនមានរថយន្តជូនកម្មករសំរាប់អ្នកផ្ទះឆ្ងាយៗ ពេលធ្វើការបន្ថែមម៉ោងដល់ម៉ោង ៨:៣០ នាទីយប់។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានរថយន្តឡើយ ព្រោះក្រុមហ៊ុនបានឧបត្ថមប្រាក់ចំនួន ៥ ដុល្លារក្នុងមួយខែសំរាប់ថ្លៃស្នាក់នៅ និងសោហ៊ុយធ្វើដំណើរសំរាប់កម្មករម្នាក់ៗរួចហើយ។

៥- សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាប្រចាំរោងចក្រនៅតែទាមទារ ឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ទៀងទាត់ចំនួន ៥ ដុល្លារ ដោយសមាមាត្រទៅនឹងចំនួនថ្ងៃដែលកម្មករអវត្តមាន។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននៅតែអនុវត្តតាមគោលការណ៍ចាស់ដដែល ករណីកម្មករណាឈប់មួយថ្ងៃចន្លោះពេល១៥ ថ្ងៃម្តង ក្រុមហ៊ុនកាត់ប្រាក់រង្វាន់ទៀងទាត់ចំនួន ២,៥ ដុល្លារ។

៦- សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាប្រចាំរោងចក្រនៅតែទាមទារ ឱ្យក្រុមហ៊ុនផ្តល់ភាពងាយស្រួលក្នុងការសុំច្បាប់ឈប់សំរាកតាមការជាក់ស្តែង។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការសុំច្បាប់ ក្រុមហ៊ុនអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ និងច្បាប់ស្តីពីការងារ។

៧- សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាប្រចាំរោងចក្រនៅតែទាមទារ ឱ្យក្រុមហ៊ុន

រៀបចំកន្លែងវាយបុងជាពីរកន្លែង ឬដាក់នាឡិកាវាយបុងនៅតាមក្រុមនីមួយៗ។ ដោយឡែកភាគីនិយោជក បញ្ជាក់ថា ក្រុមហ៊ុនមានកន្លែងវាយបុងគ្រប់គ្រាន់សំរាប់ឱ្យកម្មករប្រើប្រាស់ហើយ ។

៨- អ្នកស្រី អ៊ុំ ស្រី នៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលឱ្យដល់ ១០០ ដុល្លារ ក្នុងមួយខែ ដូចប្រធានក្រុមដទៃទៀតដែរ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ឱ្យបានឡើយ ព្រោះអ្នកស្រីពុំមានលទ្ធភាព និងសមត្ថភាពដូចប្រធានក្រុមដទៃទៀតឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាស ស្តីពីការតែងតាំង សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៤៣ ក.ប/អក/វក. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ (វេលាម៉ោង ០៩:០០ នាទី ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលសះជាចំនួន០២ចំណុច និងមិនសះជាចំនួន០៨ចំណុច ក្នុងចំណោមការទាមទារទាំងអស់ចំនួន១០ចំណុច។ ចំណុចមិនសះជាចំនួន០៨ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០៨ចំណុចនេះនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ (វេលាម៉ោង០៩:០០នាទី)។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន០៨ចំណុចនេះ ជាលទ្ធផលទទួលបានសះជាចំនួន០១ចំណុច គឺចំណុចវិវាទទី៧ ហើយ០៤ចំណុចទៀត គឺ ចំណុចវិវាទទី៣ ទី៤ ទី៥ និងទី៦ (កម្មករនិយោជិតដកការទាមទារចេញ)។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែលើចំណុចវិវាទទី១ និងទី២ (ភាគីកម្មករនិយោជិតស្នើសុំបញ្ចូលតែមួយ) និងចំណុចវិវាទទី ៨ ប៉ុណ្ណោះ ដោយផ្អែកលើភស្តុតាង និងហេតុផលដូចខាងក្រោម៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- សារណាសង្ខេបលេខ ០០៣/០៩ ញ.វ.រ.ប ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណុំរឿងលេខ ១០/០៩ ។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ញូ វ៉ាយដឺ ចុះបញ្ជិកាលេខ ៧៨ កប/អក/អធក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០៨ ។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ញូ វ៉ាយដឺ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៨។

៤- លិខិតទូទាត់ប្រាក់របស់ក្រុមហ៊ុន ញូ វ៉ាយដឺ លេខ 0613/08 រ.ប.ញ.វ ជូនចំពោះលោក អ៊ឹង លាភ ស្តីពីការទូទាត់ប្រាក់រង្វាន់តួនាទី ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៨។

៥- លិខិតជូនដំណឹងរបស់ក្រុមហ៊ុន ញូ វ៉ាយដឺ លេខ ០៦១៨/០៨ រ.ប.ញ.វ ស្តីពីការជូនដំណឹង លោក អ៊ឹង លាភ មកកាន់ការងារនៅបន្ទប់អាវគំរូ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨។

៦- លិខិតព្រមានចំនួនបីសន្លឹក ។

៧- កំណត់ហេតុសាកសួរទៅប្រធានក្រុមផ្នែកឃ្លាំងឈ្មោះ ងួន ពៅ ស្តីពីថា តើលោក អ៊ឹង លាភ មានធ្វើការអ្វីខ្លះសព្វថ្ងៃនេះ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

៨- លិខិតរបស់ក្រុមហ៊ុន ញូ វ៉ាយដឺ លេខ ០៦២៩/០៨ រ.ប.ញ.វ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការប្តឹងជំទាស់របស់កម្មករ កម្មការិនីដែលពាក់ព័ន្ធនឹងការបោះឆ្នោតបង្កើតសហជីព

ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

៩- លិខិតបដិសេធរបស់ឈ្មោះ អ៊ុំ ស្រី ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨។

១០- លិខិតបដិសេធរបស់ឈ្មោះ ឡាយ ចាន់ដារីម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

១១- លិខិតបដិសេធរបស់ឈ្មោះ ឈួយ សាមុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

១២- លិខិតបដិសេធរបស់ឈ្មោះ អ៊ិន បូផា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៣- លិខិតបដិសេធរបស់ឈ្មោះ ម៉ុយ សុធារា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៤- លិខិតបដិសេធរបស់ឈ្មោះ ស៊ឹម បុងឡាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៥- កំណត់ហេតុរបស់ឈ្មោះ ហ៊ិ ប្រុស ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៦- បញ្ជីឈ្មោះអ្នកចូលរួមបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៧- លិខិតជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យាការងារមានកំណត់ថិរវេលាឈ្មោះ អ៊ុង លាភ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៨- លិខិតជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យាការងារមានកំណត់ថិរវេលាឈ្មោះ អ៊ុង លាភ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៩- លិខិតរបស់ក្រុមហ៊ុន ញូ វ៉ាយដី លេខ ០៦៣០/០៨ រ.ប.ញ.វ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការបញ្ចប់កិច្ចសន្យាការងាររវាងក្រុមហ៊ុន និងលោក អ៊ុង លាភ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ។

២០- លិខិតស្នើសុំស្តីពីសមាជិកឈ្មោះ វៃ សុខន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨។

២១- លិខិតរបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាលេខ ១០៨/០៨ សបកក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីអំពីលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដី។

២២- លិខិតរបស់នាយកដ្ឋានវិវាទការងារ លេខ ១៣៩៤ កប/អក/វក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដី ។

២៣- លិខិតរបស់សហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរ លេខ ០៥៥/០៨ ស.ស.ក.ប.ខ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបាត់បង់សមាជិកភាពរបស់ឈ្មោះ អ៊ុង លាភ ចេញពីសហជីពកម្មករប្រជាធិបតេយ្យខ្មែរ។

២៤- លិខិតរបស់នាយកដ្ឋានវិវាទការងារ លេខ ៥៦៩ កប/អក/វក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពអាណត្តិថ្មី របស់សហជីពកម្មករប្រជាធិបតេយ្យខ្មែរ

នៃរោងចក្រ ញូ វ៉ាយដឺ ។

២៥- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃរោងចក្រ ញូ វ៉ាយដឺ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ ។

២៦- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃរោងចក្រ ញូ វ៉ាយដឺ លេខ ០១៧/០៨ ក.ប/វ.ក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ ។

២៧- លិខិតរបស់នាយកដ្ឋានវិវាទការងារ លេខ ៧៣៨ កប/អក/វក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី របស់សហជីពយុវជនខ្មែរនៃរោងចក្រ ញូ វ៉ាយដឺ ។

២៨- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរនៃរោងចក្រ ញូ វ៉ាយដឺ ។

២៩- សំណុំឯកសារបុគ្គលិកឈ្មោះ អ៊ុំ ស្រី ។

៣០- កិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ឈ្មោះ អ៊ុំ ស្រី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៨ ។

៣១- កិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ឈ្មោះ អ៊ុំ ស្រី ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- សារណាសង្ខេបលើសំណុំរឿងវិវាទការងាររួមនៃក្រុមហ៊ុន ញូវ៉ាយដឺ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ។

២- លិខិតរបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដឺ គោរពជូន លោកប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការជួយដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ញូ វ៉ាយដឺ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ។

៣- លិខិតចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ជំទាស់នឹងសារណាលេខ ០០៣/០៩ ញ.វ.រ.ប ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ភាគីក្រុមហ៊ុន ញូ វ៉ាយដឺ ។

៤- លិខិតបញ្ជាក់របស់ឈ្មោះ អ៊ុំ ស្រី ថាមិនបានចូលសហជីពណាទេ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ ។

៥- កំណត់ហេតុរបស់ឈ្មោះ សៅ សំអូន ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ ។

៦- កិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ឈ្មោះ ឆាយ សុកាន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ ។

៧- កិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ឈ្មោះ លឹម សារ៉ាត់ ។

៨- ពាក្យសុំចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដឺ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៩- កំណត់ហេតុស្តីពីការបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដឺ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១០- បញ្ជីឈ្មោះអ្នកចូលរួមបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃ

រោងចក្រ ញូ វ៉ាយដី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១១- សេចក្តីប្រកាសផ្ទាល់ខ្លួនរបស់ឈ្មោះ អ៊ឹង លាភ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១២- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ អ៊ឹង លាភ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៣- សេចក្តីប្រកាសផ្ទាល់ខ្លួនរបស់ឈ្មោះ សែម ចាន់ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៤- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ សែម ចាន់ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៥- សេចក្តីប្រកាសផ្ទាល់ខ្លួនរបស់ឈ្មោះ អ៊ុំ ស្រី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៦- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ អ៊ុំ ស្រី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៧- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១០៨/០៨ ស.ប.ក.ក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដី។

១៨- បញ្ជីរាយនាមថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

១៩- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារលេខ ១០៩/០៨ ស.ប.ក.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការមិនទទួលយកលិខិតជូនដំណឹងពីលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ញូ វ៉ាយដី និងការគំរាមកំហែងថ្នាក់ដឹកនាំសហជីពពីសំណាក់ក្រុមហ៊ុន ញូ វ៉ាយដី។

២០- បង្កាន់ដៃទទួលសំណុំរឿង ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់នាយកដ្ឋានវិវាទការងារ។

២១- កិច្ចសន្យាការងារមានកំណត់ថិរវេលា ឈ្មោះ អ៊ឹង លាភ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨។

២២- លិខិតស្តីពីការឈប់ពីការងាររបស់ឈ្មោះ អ៊ឹង លាភ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

២៣- លិខិតលាលែងពីសហជីពកម្មករប្រជាធិបតេយ្យខ្មែរ និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីបង់ជាភាគទានសហជីពរបស់ឈ្មោះ អ៊ឹង លាភ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

២៤- លិខិតលាលែងពីសហជីពកម្មករប្រជាធិបតេយ្យខ្មែរ និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីបង់ជាភាគទានសហជីពរបស់ឈ្មោះ អ៊ុំ ស្រី។

២៥- កំណត់ហេតុកិច្ចប្រជុំ ចរចារអនុសញ្ញារួមការងាររវាងរោងចក្រ ញូ វ៉ាយដី និងសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញូ វ៉ាយដី លេខ ០៤៣ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ញូ វ៉ាយដឺ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៥៣ កប/អក/លកអ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៥៤ កប/អក/លកអ. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩។

**ការរកឃើញអង្គហេតុ:**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ញូ វ៉ាយដឺ មានទីតាំងស្ថិតនៅភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានជួលកម្មករនិយោជិតសរុបចំនួនប្រហែល១ ៤០០នាក់។
- ភាគីកម្មករនិយោជិត ដែលជាភាគីនៃដើមបណ្តឹងក្នុងរឿងនេះតំណាងដោយសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ប៉ុន្តែសហជីពនេះមិនទាន់មានបញ្ជិកាទេ។ យោងតាមឯកសារដែលបានដាក់ជូនដោយកម្មករនិយោជិត បញ្ជាក់ថាមានកម្មករចំនួន១០៨នាក់បានផ្តិតមេដៃទាមទារក្នុងរឿងវិវាទនេះ។

**ចំណុចវិវាទទី១ និងទី២: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាឱ្យលោក អ៊ឹង លាភ វិញ មូលហេតុក្រុមហ៊ុនរើសអើងសហជីព**

- លោក អ៊ឹង លាភ មានតួនាទីជាអ្នកគ្រប់គ្រងឃ្លាំង និងជួយបកប្រែភាសាចិន។
- លោកត្រូវបានជួលតាមរយៈកិច្ចសន្យាការងារ ដែលមានថិរវេលាកំណត់ចំនួន៦ខែ។ កិច្ចសន្យាលើកទី១ មានថិរវេលាពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៨ ហើយកិច្ចសន្យានេះ ត្រូវបន្តសារជាថ្មី ដោយកិច្ចសន្យាលើកទី២ មានថិរវេលាពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៨។
- ក្រុមហ៊ុនបានជូនដំណឹងបញ្ចប់កិច្ចសន្យានៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយលោក អ៊ឹង លាភ បានចុះហត្ថលេខាលើលិខិតស្តីពីការលាឈប់ពីការងារ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយក្នុងលិខិតនោះ

បញ្ជាក់ពីមូលហេតុថា កិច្ចសន្យាផុតរលត់។ នៅក្នុងសវនាការលោក អ៊ឹង លាភ បានទទួលស្គាល់ថា កិច្ចសន្យារបស់គាត់ត្រូវផុតរលត់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៨ មែន ហើយលោកមិនទាន់បានបើកប្រាក់ឈ្នួលចុងក្រោយ និងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន៥ភាគរយនៃកិច្ចសន្យាលើកទី២នេះទេ។ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន៥ភាគរយនៃកិច្ចសន្យាលើកទី១ បានទូទាត់រួចហើយ នៅពេលបញ្ចប់កិច្ចសន្យាលើកទី ១។

- លោក អ៊ឹង លាភ បានទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាខ្លួនវិញពីព្រោះមូលហេតុដែលក្រុមហ៊ុនមិនបន្តកិច្ចសន្យារបស់គាត់នេះមកពីក្រុមហ៊ុនរើសអើងសហជីព។ ក្រុមហ៊ុនបានឆ្លើយតបថា ក្រុមហ៊ុនមិនមានការរើសអើងសហជីពទេ។
- លោក អ៊ឹង លាភ បានបញ្ជាក់ថា លោកធ្លាប់ជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ (បញ្ជិកាចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨)។ លោកបានលាឈប់ពីប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយនៅថ្ងៃខែឆ្នាំដដែលលោកបានជាប់ឆ្នោតជាប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ។ ការបោះឆ្នោតបានប្រព្រឹត្តនៅវេលាម៉ោង១០ព្រឹក។
- លោក អ៊ឹង លាភ បានបញ្ជាក់ថា សហជីពលោកបានជូនដំណឹងទៅ ក្រុមហ៊ុនអំពីលទ្ធផលនៃការបោះឆ្នោតនេះ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ វេលាម៉ោង១៥:៣០នាទី ប៉ុន្តែប្រធានរដ្ឋបាលរបស់ក្រុមហ៊ុនបានបដិសេធមិនទទួលលិខិតនោះទេ ដោយលើកឡើងថា លោក អ៊ឹង លាភ មានឈ្មោះក្នុងសហជីព ២ គឺលោកជាប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ផង និងជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ផង។
- នៅក្នុងសវនាការ លោក អ៊ឹង លាភ បានទទួលស្គាល់ថា លោកពិតជាមានឈ្មោះក្នុងសហជីព ២ មែនគឺលោកជាប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ផង និងជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ផង។ ប៉ុន្តែលោកបានដាក់ពាក្យលាឈប់ពីប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ និងជូនដំណឹងទៅក្រុមហ៊ុននៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨នេះដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសួរបញ្ជាក់ថា តើលោកជូនដំណឹងទៅក្រុមហ៊ុនពីការលាឈប់ពីសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ មុន (នៅម៉ោងប៉ុន្មាន) ឬជូនដំណឹងអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ មុន (ផ្អែកតាមឯកសារដែលភាគីកម្មករនិយោជិតផ្តល់ឱ្យចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨) ការបោះឆ្នោតប្រព្រឹត្តទៅនៅម៉ោង១០ព្រឹក)។ លោក អ៊ឹង លាភបានឆ្លើយថា មិនចាំទេ។

- លោក អ៊ឹង លាភ បានឆ្លើយបញ្ជាក់ថា ការលាឈប់ពីសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ នេះ លោកបានជូនដំណឹងទៅសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួចហើយ ប៉ុន្តែមិនមានឯកសារបញ្ជាក់ទេនៅពេលសវនាការ។ សហជីពបានសន្យាផ្តល់ឯកសារនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលឯកសារនោះទេ។
- លោក អ៊ឹង លាភ បានអះអាងថា នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៨ លោក តិក តែក ប្រធានរដ្ឋបាលបានគម្រាមបញ្ចប់កិច្ចសន្យាលោកដោយផ្ទាល់មាត់(លោក អ៊ឹង លាភ មិនបានផ្តល់ភស្តុតាងទេ) ហើយប្រធានរដ្ឋបាលក៏អវត្តមានពីសវនាការដែរ។
- ផ្អែកតាមលិខិតចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលផ្ញើជូននាយកដ្ឋានវិវាទការងារបានបញ្ជាក់ថាសហជីពលោកបានជូនដំណឹងទៅក្រុមហ៊ុនអំពីលទ្ធផលនៃការបោះឆ្នោតលើកទី២ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ប៉ុន្តែប្រធានរដ្ឋបាលរបស់ក្រុមហ៊ុននៅតែបដិសេធមិនទទួលលិខិតនោះដដែល។ សហជីពមិនបានបង្ហាញលិខិតជូនដំណឹងអំពីលទ្ធផលនៃការបោះឆ្នោតលើកទី២ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ នេះទេ។
- លោក អ៊ឹង លាភ បញ្ជាក់ថា ក្រោយពេលមិនបន្តកិច្ចសន្យារបស់លោក ក្រុមហ៊ុនបានបន្តកិច្ចសន្យាឱ្យ លឹម សារ៉ាត់ និងបានរើសកម្មករផ្នែកដេរជាច្រើននាក់ទៀត ហើយបានឱ្យ លឹម សារ៉ាត់ មកជំនួសកន្លែងការងាររបស់លោក (តាមការអះអាងរបស់លោក អ៊ឹង លាភ បញ្ជាក់ថា កិច្ចសន្យារបស់ លឹម សារ៉ាត់ បញ្ចប់ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨)។ បន្ថែមពីនេះក្រុមហ៊ុនក៏មិនបន្តកិច្ចសន្យារបស់អនុប្រធានសហជីពឈ្មោះ សែម ចាន់ ដែរ តាមការអះអាងរបស់លោក អ៊ឹង លាភ កិច្ចសន្យារបស់ សែម ចាន់ បញ្ចប់នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០០៨)។
- លោក អ៊ឹង លាភ បានបញ្ជាក់ថា លោកធ្លាប់ត្រូវបានក្រុមហ៊ុនព្រមានម្តងនៅពេលចូលឆ្នាំចិន នៅឆ្នាំ ២០០៨ មូលហេតុលោកឈប់អត់ច្បាប់។
- ផ្អែកលើសារណារបស់ក្រុមហ៊ុនចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ក្រុមហ៊ុនបញ្ជាក់ថា មូលហេតុ ដែលក្រុមហ៊ុនមិនបន្តកិច្ចសន្យារបស់លោក អ៊ឹង លាភ ដោយសារគាត់មិនគោរពតាមបទបញ្ជាផ្ទៃក្នុងរោងចក្រ និងកំណត់ហេតុ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ (ផ្អែកលើកំណត់ហេតុ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០០៨ នេះ លោក អ៊ឹង លាភ ជាសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ធ្វើការផ្នែកឃ្លាំង បានឯកភាពធ្វើការផ្លាស់ប្តូរការងារទៅធ្វើការនៅបន្ទប់គំរូតាមការចាត់តាំងរបស់ក្រុមហ៊ុន។ ចំណែកភាគីក្រុមហ៊ុនបានឯកភាពរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនលោក អ៊ឹង លាភ ឱ្យនៅដដែល ហើយក្រុមហ៊ុនបានបើកប្រាក់រំលឹកនូវប្រាក់គួនាទីចាប់ពីខែមករា រហូតដល់ខែកក្កដា ឆ្នាំ២០០៨ ហើយបើកប្រាក់នៅថ្ងៃទី២៣ ខែ

សីហា ឆ្នាំ២០០៨) ។ ផ្អែកលើសារណារបស់ក្រុមហ៊ុនចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩ ក្រុមហ៊ុនបានបើកប្រាក់នោះរួចហើយ។ ទាក់ទងនឹងការបើកប្រាក់រំលឹកនេះ ភាគីកម្មករនិយោជិតមិនបានជំទាស់ទេ នៅក្នុងសារណាតបរបស់ខ្លួន ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩។

- យោងតាមសារណារបស់ក្រុមហ៊ុន ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៨ មានការប្រជុំរវាងប្រធានរោងចក្រជាមួយលោក អ៊ឹង លាភ និងប្រធានរដ្ឋបាល ហើយលោក អ៊ឹង លាភ នៅតែប្រកែកមិនព្រមទៅធ្វើការនៅបន្ទប់គំរូដដែល។
- នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ ប្រធានរោងចក្របានជូនដំណឹងឱ្យលោក អ៊ឹង លាភ មកធ្វើការនៅបន្ទប់គំរូ ចាប់ពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៨ វេលាម៉ោង៧:០០កុំបីខាន។
- នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ លោក អ៊ឹង លាភ បានគំរាមមេការនៅបន្ទប់គំរូ (កំណត់ហេតុថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨) ។ ភាគីកម្មករនិយោជិតបានបដិសេធចំណុចនេះ នៅក្នុងសារណាតបរបស់ខ្លួន ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយបានបញ្ជាក់ថា លោក អ៊ឹង លាភ មិនបានគំរាមមេការទេ ហេតុការណ៍ដែលបានកើត ឡើងនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ គឺជាការលេងសើចជាមួយគ្នាទៅវិញទៅមកទេ។
- កំណត់ហេតុចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់លោក លឹម សារ៉ាត់ និង ងួន ពៅ និងលិខិតចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់លោក អ៊ឹង លាភ ដែលក្រុមហ៊ុនបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល បញ្ជាក់ថា ហេតុការណ៍ដែលបានកើតឡើង នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ មិនមែនជាការគំរាមកំហែងទេ។
- នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ លោក អ៊ឹង លាភ បានបញ្ជូនលិខិតមួយមកផ្នែកគ្រប់គ្រងរោងចក្រស្នើសុំដកភាគទានសហជីពកម្មករប្រជាធិបតេយ្យខ្មែរចំនួន៥០ភាគរយ (សូមមើលលិខិតចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ របស់ អ៊ឹង លាភ) ។
- នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដី បានទទួលបង្កាន់ដៃចុះបញ្ជិកា ។
- នៅថ្ងៃទី២៧ និង ២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមហ៊ុនបានទទួលលិខិតបដិសេធមួយចំនួនរបស់កម្មករនិយោជិតដែលត្រូវបានគេយកឈ្មោះ និងហត្ថលេខាទៅប្រើដោយមិនដឹងខ្លួន មានដូចជា អ៊ុំ ស្រី ជាលេខាសហជីព, ឈួន សាម៉ុន, ឡាយ ចាន់ដារីម, ឈួម សាមុត, អ៊ន់ បូផា មុយ សុភាព ស៊ឹម បុងឡាយ, ហ៊ បុស បានបដិសេធថា មិនបានចូលរួមបោះឆ្នោតជ្រើសរើសសហជីពទេ។ ប៉ុន្តែភាគីកម្មករនិយោជិតបានបដិសេធចំពោះលិខិតបដិសេធរបស់អ្នកស្រី អ៊ុំ ស្រី ដោយមានលិខិតបញ្ជាក់របស់អ្នកស្រីចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ ថា អ្នកស្រីនៅតែជាលេខាសហជីពនៃសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដី។

- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមហ៊ុនបានដាក់ពាក្យទៅនាយកដ្ឋានវិវាទការងារ ប្តឹងជំទាស់នឹងការបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ដោយមានកម្មករមួយចំនួនធ្វើលិខិតបដិសេធលោក អ៊ឹង លាភ មានឈ្មោះជាប្រធានសហជីពចំនួនពីរ និង សែម ចាន់ ដែលជាអនុប្រធានសហជីព ធ្វើការមិនទាន់គ្រប់មួយឆ្នាំ( សែម ចាន់ ចូលធ្វើការនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨) ។
- នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ក្រុមហ៊ុនបានទទួលលិខិតជូនដំណឹងអំពីលទ្ធផលនៃការបោះឆ្នោតចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ពីលោក សួង ខាយស៊ុ។
- នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ប្រធាននាយកដ្ឋានវិវាទការងារបានធ្វើលិខិតជូនលោក អ៊ឹង លាភ ទាក់ទងនឹងការបដិសេធមិនចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរដោយសារលិខិតបដិសេធរបស់ អ៊ុំ ស្រី ជាលេខាសហជីពចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨។
- នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ ប្រធានសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរបានជូនដំណឹងក្រុមហ៊ុនស្តីពីការបណ្តេញលោក អ៊ឹង លាភ ពីសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ដែលមានអានុភាពចាប់តាំងពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨។

**ចំណុចវិវាទទី ៨ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលឱ្យដល់១០០ដុល្លារអាមេរិក ក្នុងមួយខែឱ្យអ្នកស្រី អ៊ុំ ស្រី ផ្អែកតាមកំណត់ហេតុកិច្ចប្រជុំចរចាអនុសញ្ញារួមចុះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨**

- អ្នកស្រី អ៊ុំ ស្រី មានតួនាទីជាប្រធានក្រុម K២ ហើយទទួលបានប្រាក់ឈ្នួល ៩០ ដុល្លារអាមេរិកក្នុងមួយខែ។ អ្នកស្រីទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលឱ្យដល់១០០ដុល្លារអាមេរិកក្នុងមួយខែផ្អែកតាមកំណត់ហេតុកិច្ចប្រជុំចរចាអនុសញ្ញារួមចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។ ចំណុចទី ២ នៃកំណត់ហេតុនេះចែងថា " ក្រុមហ៊ុនកំណត់រយៈពេលត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ក្នុងការរៀបចំឱ្យមានមេការគ្រប់គ្រងក្រុម K២ ហើយប្រធានក្រុមឈ្មោះ អ៊ុំ ស្រី ត្រូវសហការស្តាប់ការបែងចែកការងាររបស់មេការថ្មី និងមិនត្រូវបង្អាប់កូនក្រុមមិនឱ្យសហការការងារជាមួយមេការថ្មីឡើយ។ បើផុតរយៈពេលនេះពុំមានមេការមកគ្រប់គ្រងក្រុម K២ ទេ ឈ្មោះ អ៊ុំ ស្រី នឹងតម្លើងជាប្រធានក្រុមធំ ដោយស្វ័យប្រវត្តិព្រមទាំងទទួលបានប្រៀវត្សបន្ថែមដូចប្រធានក្រុមធំដទៃទៀតដែរ។"
- តាមការអះអាងរបស់ភាគីកម្មករនិយោជិត និងក្រុមហ៊ុនប្រធានក្រុមធំទទួលបានប្រៀវត្សចំនួន១០០ដុល្លារអាមេរិកក្នុងមួយខែ។
- នៅក្នុងសវនាការ កម្មករ អ៊ុំ ស្រី បានអះអាងថា ចាប់តាំងពីមានអនុសញ្ញារួមនោះ រហូតមកដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ទើបមានមេការមកគ្រប់គ្រងក្រុម K២ ម្យ៉ាងទៀត ក្នុងអំឡុងពេលគ្មានមេការនោះ

ក្រុម K២ ធ្វើការតែងតែទទួលបានរង្វាន់សម្រាប់លទ្ធផលការងារល្អ។ ភាគីនិយោជកដែលមានវត្តមានក្នុងសវនាការមិនបានបដិសេធនឹងការលើកឡើងនេះទេ ហើយបានឆ្លើយតបថា ក្រុមហ៊ុននឹងពិនិត្យមើលឯកសាររបស់ក្រុមហ៊ុន ក្រោយពេលចេញពីសវនាការនេះទៅ បើសិនជាត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ មិនមានមេការមកគ្រប់គ្រងក្រុម K២ នេះទេ ក្រុមហ៊ុននឹងតម្លើងប្រាក់ឈ្នួលឱ្យកម្មករ អ៊ុំ ស្រី ។

- ក្រុមហ៊ុនបានដាក់ឯកសារមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាកំណត់ត្រាសម្គាល់មេការទាំងបីរូប ដែលមានរៀបរាប់ឈ្មោះនៅក្នុងសារណារបស់ក្រុមហ៊ុនខាងក្រោម ប៉ុន្តែឯកសារជាភាសាចិន ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើឯកសារនេះឡើយ ។
- ផ្អែកតាមសារណារបស់ក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនទទួលស្គាល់កំណត់ហេតុកិច្ចប្រជុំចរចាអនុសញ្ញារួមចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ នោះ ប៉ុន្តែក្រុមហ៊ុនមិនអាចតម្លើងប្រាក់ឈ្នួលឱ្យឈ្មោះ អ៊ុំ ស្រី បានទេ ព្រោះគាត់ធ្វើការមិនចុះសម្រុងគ្នាជាមួយមេការថ្មីឈ្មោះ Ju Hong Mei ដែលក្រុមហ៊ុនបានចាត់តាំងឱ្យចូលកាន់ការងារនៅក្រុម K២ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ ព្រមទាំងមេការថ្មីពីរនាក់ទៀត ដែលក្រុមហ៊ុនបានប្តូរមកជំនួសគឺឈ្មោះ Fan Xia Fang នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ និងឈ្មោះ Cai Mu Fing ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។
- ក្នុងសារណាតបរបស់ភាគីកម្មករនិយោជិតបានបញ្ជាក់ថា មិនមានមេការមកគ្រប់គ្រងក្រុម K២ មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ទេ គឺមេការបានមកគ្រប់គ្រងក្រុម K២ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ គឺ នៅ ១០ថ្ងៃ ក្រោយពីថ្ងៃកំណត់នៅក្នុងអនុសញ្ញារួម ហេតុដូច្នេះក្រុមហ៊ុនត្រូវអនុវត្តតាមការព្រមព្រៀងនោះ គឺត្រូវតម្លើងប្រាក់ឈ្នួលកម្មករ K២ ឱ្យស្មើនឹងប្រធានក្រុមធំផ្សេងទៀត។ ប៉ុន្តែនៅក្នុងសារណាតបនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញការជំទាស់របស់ភាគីកម្មករនិយោជិតទៅនឹងការលើកឡើង របស់ក្រុមហ៊ុនដែលថា មានមេការជនជាតិចិនឈ្មោះ Ju Hong Mei មកកាន់ការងារនៅក្រុម K២ នៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨ នោះទេ។

## **ហេតុផលនៃសេចក្តីសម្រេច**

**ចំណុចវិវាទទី១ និងទី២: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាឱ្យលោក អ៊ីង លាភ វិញ មូលហេតុក្រុមហ៊ុនរើសអើងសហជីព**

ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានអះអាងថា មូលហេតុមួយដែលនិយោជកមិនបន្តកិច្ចសន្យាឱ្យលោក អ៊ីង លាភ គឺមានការរើសអើងសហជីព ប្រឆាំងនឹងសហជីព ប៉ុន្តែភាគីនិយោជកបានបង្ហាញថា ការមិនបន្តកិច្ចសន្យានេះមិនមានការរើសអើងសហជីពនោះទេ ហើយមូលហេតុដែលមិនបន្តនោះដោយសារលោក អ៊ីង លាភ បានបំពានបទបញ្ជាផ្ទៃក្នុង មិនស្តាប់តាមការចាត់តាំងរបស់ក្រុមហ៊ុន ហើយកិច្ចសន្យារបស់គាត់ដល់ពេលផុតរលត់។ ហេតុនេះក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាដូចខាងក្រោម:

6

១- តើការសម្រេចមិនបន្តកិច្ចសន្យាការងារ លោក អ៊ឹង លាភ មានការរើសអើងសហជីពឬទេ?

២- តើក្រុមហ៊ុនបានជូនដំណឹងបញ្ចប់កិច្ចសន្យាការងារត្រឹមត្រូវដែរឬទេ?

**ក-តើការសម្រេចមិនបន្តកិច្ចសន្យាការងារ លោក អ៊ឹង លាភ មានការរើសអើងសហជីព ឬទេ?**

តាមមាត្រា ១២ នៃច្បាប់ស្តីពីការងារបានចែងថា *"..... គ្មាននិយោជកណាម្នាក់អាចយកបញ្ហាការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីសំរេចអំពី ....... ការជួល ...... ការផ្តាច់កិច្ចសន្យាការងារ ....."* ។

ទាក់ទងនឹងការរើសអើងសហជីព នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិតចូលធ្វើការវិញ ដោយសារការបញ្ឈប់កម្មករទាំងអស់នោះមានការរើសអើងសហជីពដែលបំពាននឹងមាត្រា ១២ និង២៧៩ នៃច្បាប់ស្តីពីការងារ ដែលហាមឃាត់និយោជកមិនឱ្យយកហេតុផលនៃការចូលជាសមាជិកសហជីព ឬការធ្វើសកម្មភាពសហជីព ដើម្បីជួល ឬដាក់វិន័យ ឬផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតរបស់ខ្លួនឡើយ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៨/០៧-ដេ ហ្វាង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ និងលេខ១២៣/០៧-អ៊ីហ្គាមេន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ១)* ។

ផ្អែកលើអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លោក អ៊ឹង លាភ ជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ (បញ្ជិកាសហជីពចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨) នៅមុនពេលជាប់ឆ្នោត ជាប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ញូ វ៉ាយដឺ ហើយកិច្ចសន្យាលើកទី១ របស់លោកពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានក្រុមហ៊ុនបន្តកិច្ចសន្យាថ្មី ដែលមានថិរវេលា៦ខែ គិតពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៨។

ផ្អែកលើអង្គហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លោក អ៊ឹង លាភ ធ្លាប់ត្រូវបានក្រុមហ៊ុនបន្តកិច្ចសន្យាការងាររបស់លោក នៅពេលដែលលោកមានមុខនាទីជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃក្រុមហ៊ុន ញូ វ៉ាយដឺ (បញ្ជិកាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨)។ ទើបតែកិច្ចសន្យាលើកទី២នេះទេ ដែលក្រុមហ៊ុនសម្រេចមិនបន្តកិច្ចសន្យាឱ្យលោកសារជាថ្មី។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ថាការមិនបន្តកិច្ចសន្យាលើកទី២នេះ គឺដោយសារតែការចូលរួមសហជីពឡើយ ព្រោះលោកជាធ្លាប់ជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែររួចហើយ ហើយលោកបានចូលរួមបង្កើតសហជីពមួយទៀត។ បន្ថែមពីនេះសហជីពថ្មីនេះ ក្រសួងទទួលបន្ទុកវិស័យការងារមិនបានចុះបញ្ជិកាឱ្យទេ ដោយសារបញ្ហាមិនប្រក្រតីទាក់ទងនឹងការបោះឆ្នោត ដូចជាការបដិសេធរបស់ អ៊ុំ ស្រី ក្នុងតួនាទីជាលេខាធិការសហជីព។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញា

កណ្តាលរកឃើញថា តាមរយៈសារណារបស់ក្រុមហ៊ុនមិនបន្តគឺដោយសារតែលោក អ៊ឹង លាភ មិនព្រមស្តាប់តាមការចាត់តាំងរបស់ក្រុមហ៊ុន ដែលបានផ្លាស់លោកទៅធ្វើការនៅបន្ទប់គំរូ តាមកិច្ចព្រមព្រៀងរវាងលោក និងក្រុមហ៊ុន ហើយភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងរបស់និយោជកត្រង់ចំណុចនេះដែរ ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនបន្តកិច្ចសន្យាការងាររបស់លោក អ៊ឹង លាភ មិនមែនមកពីមូលហេតុនៃការរើសអើងសហជីព ។

**ខ- តើក្រុមហ៊ុនបានជូនដំណឹងទៅលោក អ៊ឹង លាភ ត្រឹមត្រូវដែរឬទេ?**

កថាខ័ណ្ឌ២ នៃមាត្រា៦៧ នៃច្បាប់ការងារចែងថា *"កិច្ចសន្យាការងារដែលធ្វើឡើងដោយការព្រមព្រៀងគ្នា ដោយមានកំណត់ថិរវេលាពិតប្រាកដមិនអាចមានរយៈពេលលើសពីពីរឆ្នាំបានឡើយ ។ កិច្ចសន្យានេះអាចបន្តសារជាថ្មីម្តង ឬច្រើនដងបាន ដរាបណាការបន្តសារជាថ្មីនោះមានថិរវេលាអតិបរមាមិនលើសពីពីរឆ្នាំទេ "* ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ករណី អ៊ឹង លាភ នេះបានធ្វើការតិចជាងរយៈពេល ២ ឆ្នាំ (បូកបញ្ចូលគ្នានូវថិរវេលានៃកិច្ចសន្យាដើម និងថិរវេលានៃកិច្ចសន្យាបន្តសារជាថ្មី) ។

មាត្រា ៧៣ នៃច្បាប់ការងារឆ្នាំ១៩៩៧ ចែងថា *" កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ត្រូវផុតរលត់តាមធម្មតានូវពេលដល់កាលកំណត់ ។..."*

នៅក្នុងសំណុំរឿងលេខ ១០០/០៧-ហួយៀ ខេមបូឌា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា *" ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់ជាស្វ័យប្រវត្តិនៅពេលដល់កាលកំណត់ ។ មានន័យថា កាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិត ត្រូវបានផុតរលត់ ។ ដូច្នេះមិនមែនភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង ។"* (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ១០០/០៧-ហួយៀ ខេមបូឌា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺកំណត់ថិរវេលាត្រូវផុតរលត់ជាស្វ័យប្រវត្តិនៅពេលដល់កាលកំណត់ហើយកាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិតត្រូវបានផុតរលត់ ។ ដូច្នេះមិនមែនភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង ។

ប៉ុន្តែ មាត្រា ២៩៣ នៃច្បាប់ការងារចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬ រាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើបានលុះត្រាណាតែមានការយល់ព្រមពីអធិការការងារ ។..."*

ប្រការ៣ កថាខ័ណ្ឌទី៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា *" កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការ*

*ពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល ៤៥ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះនៅរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ។ "*

បន្ថែមលើសពីនេះទៀត ប្រការ៤ កថាខណ្ឌទី១ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា *"ចាប់តាំងពីពេលដាក់ពាក្យចុះបញ្ជិកាសហជីពកម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា ត្រូវបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេលរហូតដល់៣០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះបញ្ជិកាសហជីព "* ។

តាមខ្លឹមសារនៃប្រការ៣ កថាខ័ណ្ឌទី៣ និងប្រការ៤ កថាខ័ណ្ឌទី១ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតទាំងអស់ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីព ក្នុងអំឡុងពេលសុំចុះបញ្ជិកាសហជីព ត្រូវបានទទួលការការពារពីការបញ្ឈប់ពីការងារ ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានជូនដំណឹងអំពីការផុតរលត់នៃកិច្ចសន្យាការងារ និងការមិនបន្តកិច្ចសន្យាការងារសារជាថ្មីទៀតទៅកម្មករនិយោជិត ដែលបានអះអាងថា ជាថ្នាក់ដឹកនាំសហជីព។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា ទង្វើនេះជាការបញ្ចប់កិច្ចសន្យាការងារតាមកាលបរិច្ឆេទផុតរលត់នៃកិច្ចសន្យា និងការមិនបន្តកិច្ចសន្យាសារជាថ្មីទៀត ប៉ុន្តែនេះមិនមែនជាការបញ្ឈប់កម្មករនិយោជិតពីការងារនោះទេ ដោយហេតុថា ការបញ្ឈប់មានន័យថា និយោជកផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតក្នុងអំឡុងពេល ដែលកិច្ចសន្យាកំពុងអនុវត្ត និងដែលមិនទាន់ដល់កាលផុតកំណត់នៃកិច្ចសន្យា។ ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ មិនអាចយកមកអនុវត្តលើករណីនៃការផុតរលត់កិច្ចសន្យាបានទេ ព្រោះថា មាត្រានេះបានចែងយ៉ាងច្បាស់ អំពីការការពារប្រឆាំងនឹងការបញ្ឈប់ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពពីការងាររបស់និយោជក និងមិនបានរាប់បញ្ចូលអំពីស្ថានភាពដែលកិច្ចសន្យាការងារផុតរលត់ ។

មាត្រា ៧៣ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការងារចែងថា *" ប្រសិនបើកិច្ចសន្យាមានកំណត់ថិរវេលាលើសពីប្រាំមួយខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុនចំនួនដប់ថ្ងៃអំពីការផុតរលត់នៃកិច្ចសន្យា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យា ។ រយៈពេលជូនដំណឹងមុននេះ ត្រូវកំណត់ឱ្យដល់ដប់ប្រាំថ្ងៃចំពោះកិច្ចសន្យាដែលមានថិរវេលាលើសពីមួយឆ្នាំ ។ បើគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាស្មើគ្នានឹងថិរវេលាដែលបានចុះកិច្ចសន្យាគ្រាដំបូង ឬត្រូវចាត់ទុកថាជាកិច្ចសន្យាគ្មានកំណត់ថិរវេលាពិតប្រាកដ បើថិរវេលាសរុបនៃការបន្តកិច្ចសន្យានោះលើសពីថិរវេលា ដែលមានកំណត់ក្នុងមាត្រា៦៧ ។"*

៤

មាត្រាខាងលើនេះ មានន័យថា ប្រសិនបើកិច្ចសន្យាការងារមានកំណត់ថិរវេលាលើសពី៦ខែត្រូវជូនដំណឹង១០ថ្ងៃមុនថ្ងៃផុតរលត់នៃកិច្ចសន្យា ហើយអាចបកស្រាយបានថា ប្រសិនបើកិច្ចសន្យាការងារមានកំណត់ថិរវេលា៦ខែចុះ គឺមិនចាំបាច់មានការជូនដំណឹងជាមុនទេ។

ក្នុងករណីនេះ កិច្ចសន្យារបស់ អ៊ឹង លាភ ផុតរលត់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយត្រូវបាននិយោជកជូនដំណឹងអំពីការផុតរលត់កិច្ចសន្យាការងារ និងការមិនបន្តកិច្ចសន្យាសារជាថ្មីទៀត នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយលោកបានទទួលប្រាក់៥ភាគរយម្តងរួចហើយនៅពេលផុតរលត់កិច្ចសន្យាលើកទី១។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការជូនដំណឹងរបស់និយោជកក្នុងការសម្រេចមិនបន្តកិច្ចសន្យារបស់ អ៊ឹង លាភ ត្រឹមត្រូវតាមច្បាប់។

ដូច្នេះក្រុមហ៊ុនមិនមានកាតព្វកិច្ចទទួលយកលោក អ៊ឹង លាភ ចូលធ្វើការវិញទេ។ ប៉ុន្តែតាមរយៈអង្គហេតុ គឺលោក អ៊ឹង លាភ មិនទាន់ទទួលបានប្រាក់បំណាច់៥ភាគរយចំពោះកិច្ចសន្យាទី២នៅឡើយទេ ហេតុនេះក្រុមហ៊ុនត្រូវផ្តល់នូវប្រាក់បំណាច់៥ភាគរយឱ្យលោកអ៊ឹង លាភ តាមផ្លូវច្បាប់។

**ចំណុចវិវាទទី ៨ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលឱ្យដល់១០០ដុល្លារអាមេរិកក្នុងមួយខែឱ្យអ្នកស្រី អ៊ុំ ស្រី ផ្អែកតាមកំណត់ហេតុកិច្ចប្រជុំចរចាអនុសញ្ញារួមចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨**

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលឱ្យដល់១០០ដុល្លារអាមេរិកក្នុងមួយខែឱ្យអ្នកស្រី អ៊ុំ ស្រី ដោយផ្អែកលើកិច្ចព្រមព្រៀងចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។ ប៉ុន្តែក្រុមហ៊ុនមិនយល់ព្រមផ្តល់ឱ្យតាមការស្នើសុំទេ ដោយលើកឡើងថា លោកស្រីមានទំនាស់ជាមួយនឹងមេការថ្មី។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើអ្នកស្រី អ៊ុំ ស្រី មានសិទ្ធិទទួលបានការតម្លើងប្រាក់ឈ្នួលឱ្យដល់១០០ដុល្លារអាមេរិកក្នុងមួយខែឬទេ ។

ផ្អែកតាមកំណត់ហេតុកិច្ចប្រជុំចរចាអនុសញ្ញារួមចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ចំណុចទី២នៃកំណត់ហេតុនេះចែងថា " *ក្រុមហ៊ុនកំណត់រយៈពេលត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ក្នុងការរៀបចំឱ្យមានមេការគ្រប់គ្រងក្រុម K២ ហើយប្រធានក្រុមឈ្មោះ អ៊ុំ ស្រី ត្រូវសហការស្តាប់ការបែងចែកការងាររបស់មេការថ្មី និងមិនត្រូវបង្គាប់កូនក្រុមឱ្យមិនសហការការងារជាមួយមេការថ្មីឡើយ។ បើផុតរយៈពេលនេះពុំមានមេការ មកគ្រប់គ្រងក្រុម K២ ទេ ឈ្មោះ អ៊ុំ ស្រី នឹងតម្លើងជាប្រធានក្រុមធំដោយស្វ័យប្រវត្តិ ព្រមទាំងទទួលបានបៀវត្សបន្ថែមដូចប្រធានក្រុមធំដទៃទៀតដែរ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តាមរយៈកិច្ចព្រមព្រៀងខាងលើ កម្មករនិយោជិតឈ្មោះ អ៊ុំ ស្រី អាចឡើងតួនាទីជាប្រធានក្រុមធំថ្មីបាន លុះត្រាតែខ្លួនសហការស្តាប់ការបែងចែកការងារថ្មីរបស់មេការថ្មី ហើយបើផុតរយៈពេលនេះមិនមានមេការថ្មីមកជំនួសទេ លោកស្រី អ៊ុំ ស្រី ត្រូវបានឡើងតម្លើងឋានៈជាស្វ័យប្រវត្តិ។

ផ្អែកតាមការអះអាងរបស់លោកស្រី អ៊ុំ ស្រី លោកស្រីបានបញ្ជាក់ថា ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ត្រូវបានកន្លងផុតហើយ ហើយក៏មិនទាន់មានមេការថ្មីមកជំនួសដែរ រហូតដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ទើបមាន ហេតុនេះលោកស្រីគួរតែត្រូវបានក្រុមហ៊ុនតម្លើងជាប្រធានក្រុមធំ។ ប៉ុន្តែក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសារណារបស់ខ្លួនថា ក្រុមហ៊ុនបានរកមេការថ្មីមកកាន់ក្រុម K២ ហើយ ប៉ុន្តែលោកស្រី អ៊ុំ ស្រី មិនស្តាប់តាមការណែនាំរបស់មេការថ្មីទេ ថែមទាំងបង្ករឿងជាមួយមេការថ្មីជាច្រើននាក់ទៀត។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនពិតជាបានដាក់មេការម្នាក់មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ គឺនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ ប៉ុន្តែលោកស្រី អ៊ុំ ស្រី មិនបានសហការ និងស្តាប់តាមការណែនាំរបស់មេការថ្មីនេះទេ។ ម្យ៉ាងវិញទៀតក្នុងសារណាតបរបស់ភាគីកម្មករនិយោជិត ដែលដាក់មកនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ មិនបានលើកឡើងជំទាស់ឱ្យចំៗ ចំពោះការលើកឡើងរបស់ក្រុមហ៊ុនពីមេការថ្មីឈ្មោះ Ju Hong Mei ដែលក្រុមហ៊ុនបានចាត់តាំងឱ្យចូលកាន់ការងារនៅក្រុម K២ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ ពោលគឺមុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ នោះទេ លើកឡើងតែមេការពីរនាក់ដែលចូលក្រោយថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ទៅវិញ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌ( មិនមានមេការជនជាតិចិនមកកាន់ការងារ ត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ នៅក្រុម K2 និង លោកស្រី អ៊ុំ ស្រី ត្រូវសហការ និង ស្តាប់ការណែនាំរបស់មេការថ្មី) ដែលបានព្រមព្រៀងតាមកំណត់ហេតុប្រជុំ ចុះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ មិនត្រូវបានបំពេញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានធ្វើត្រឹមត្រូវតាមកំណត់ហេតុកិច្ច ប្រជុំចរចាអនុសញ្ញារួមចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលឱ្យដល់១០០ដុល្លារអាមេរិកក្នុងមួយខែដល់ឈ្មោះ អ៊ុំ ស្រី។

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ និងទី២ :**

បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាឱ្យលោក អ៊ឹង លាភវិញ។

**ចំណុចវិវាទទី៨ :**

បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលរបស់អ្នកស្រី អ៊ុំ ស្រី ឱ្យដល់១០០ដុល្លារអាមេរិកក្នុងមួយខែ។

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **កៅ ថាច**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ------------------------------